# សេចក្តីប្រកាសព័ត៌មាន

**រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០** - អង្គការតម្លាភាពកម្ពុជា និងអង្គការអាក់សិនអេតកម្ពុជា បានប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយហិរញ្ញវត្ថុដល់អង្គការដៃគូ ដើម្បីអនុវត្តកម្មវិធីយុទ្ធសាស្ត្ររយៈពេល ៣ឆ្នាំ (២០២០-២០២២)។ នៅក្នុងពិធីចុះហត្ថលេខានេះ អង្គការតម្លាភាពកម្ពុជា និងអង្គការអាក់សិនអេតកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់ជំនួយហិរញ្ញវត្ថុដល់អង្គការដៃគូអនុវត្តគម្រោងសរុបចំនួន ៩ស្ថាប័ន ដែលនឹងរួមចំណែកនៅក្នុងការអនុវត្តកម្មវិធីយុទ្ធសាស្ត្រនេះ។

អង្គការតម្លាភាពកម្ពុជាបានទទួលមូលនិធិស្នូលពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត (SIDA) ដើម្បីអនុវត្តកម្មវិធីយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំនេះ ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងការប្រឆាំងអំពើពុករលួយ។ ជាការចូលរួមបន្ថែម អង្គការតម្លាភាពកម្ពុជា និងអង្គការអាក់សិនអេតកម្ពុជា ក៏ទទួលបានមូលនិធិពីសហភាពអឺរ៉ុប (EU) ដើម្បីអនុវត្តគម្រោងមួយដែលមានរយៈពេល ៣ឆ្នាំ "**ពង្រឹងសិទ្ធិអំណាចរបស់ស្ត្រីវ័យក្មេង ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងជំរុញការផ្តល់សេវាសាធារណៈឱ្យកាន់តែមានគណនេយ្យភាព**"។ គម្រោងនេះបាននិងកំពុងអនុវត្តនៅរាជធានីភ្នំពេញ និងនៅខេត្តគោលដៅចំនួន ៩ ដែលបានចាប់អនុវត្តកាលពីខែមករា ឆ្នាំ២០២០ និងត្រូវបញ្ចប់នៅខែធ្នូ ឆ្នាំ២០២២ ជាមួយកញ្ចប់ថវិកាសរុបចំនួនជាង ២ លានអឺរ៉ូ។ កម្មវត្ថុចម្បងនៃការអនុវត្តគម្រោងនេះ គឺដើម្បីបង្កើតបរិយាកាសអំណោយផល និងពង្រឹងសិទ្ធិអំណាចយុវជន ជាពិសេសស្ត្រីវ័យក្មេង ក្នុងការចូលរួមសកម្មភាពក្នុងដំណើរការសម្រេចចិត្ត ដើម្បីពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ជាពិសេសយកចិត្តទុកដាក់លើតម្រូវការយេនឌ័រ និងតាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាបែបច្នៃប្រឌិត និងផ្តល់ឱកាស ដើម្បីចូលរួមក្នុងកិច្ចពិភាក្សាជាមួយមន្ត្រីទទួលបន្ទុកក្នុងការសម្រេចចិត្ត និងមន្ត្រីផ្តល់សេវាសាធារណៈនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សកម្មភាពដ៏សំខាន់មួយនៅក្នុងគម្រោងនេះ គឺការផ្តល់ជំនួយហិរញ្ញវត្ថុដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការសហគមន៍ ក្រុមយុវជន និងប្រព័ន្ធផ្សព្វផ្សាយ។ ស្ថាប័នទាំងនេះ គឺជាតួអង្គដ៏សំខាន់ ដែលអាចផ្សព្វផ្សាយ និងធ្វើការជាមួយក្រុមគោលដៅបានទូលំទូលាយទៅតាមតំបន់ប្រតិបត្តិការសកម្មភាពរបស់ខ្លួន ជាពិសេសជាមួយប្រជាពលរដ្ឋ ដែលមិនសូវត្រូវបានយកចិត្តទុកដាក់។

ជាលទ្ធផល តាមរយៈការជ្រើសរើសយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ អង្គការតម្លាភាពកម្ពុជា និងអង្គការអាក់សិនអេតកម្ពុជា បានជ្រើសរើសស្ថាប័នដៃគូចំនួន ៧ រួមមាន៖ សម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) ក្រុមយុវជនកាហ្វេនយោបាយ (Politikoffee) អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV) អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា (CCSP) អង្គការមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា (CWDCC) ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) និងសារព័ត៌មានអេឡិចត្រូនិកថ្មីៗ (Thmeythmey.com) ដើម្បីអនុវត្តសកម្មភាពមួយចំនួនដែលរួមចំណែកដល់ការសម្រេចបាននូវលទ្ធផលរំពឹងទុករបស់គម្រោងនេះ។

*លោក ហុង រស្មី នាយកប្រចាំប្រទេសនៃអង្គការអាក់សិនអេតកម្ពុជា បានលើកឡើងថា ៖ គម្រោងនេះនឹងរួមចំណែកពង្រឹងកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល និងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ ក្នុងការកសាងសមត្ថភាព*

*ក៏ដូចជាលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការតាមដានការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន។ នៅក្នុងសកម្មភាពស្នូលនៃគម្រោងនេះ យុវជននឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់គណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងឆ្លើយតបនឹងតម្រូវការយេនឌ័រ។ ដូច្នេះហើយតួមានរបស់អង្គការសង្គមស៊ីវិល ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងយុវជន នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអនុវត្តគម្រោងនេះ។*

នៅក្នុងពិធីចុះហត្ថលេខានេះដែរ អង្គការតម្លាភាពកម្ពុជា ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូដើម្បីបន្តការគាំទ្រដល់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ) និងសហព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម (FASMEC)។ អង្គការតម្លាភាពកម្ពុជា នឹងបន្តកិច្ចសហការជាមួយស៊ីខៅឌូ ដើម្បីបន្តពង្រឹងភាពជាអ្នកដឹកនាំសហជីពជាស្ត្រី នៅក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹង និងកសាងសមត្ថភាព ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងសហជីព ក៏ដូចជាលើកកម្ពស់អភិបាលកិច្ចនៅក្នុងវិស័យកាត់ដេរឱ្យកាន់តែប្រសើរឡើង។ លើសពីនេះទៀត អង្គការតម្លាភាពកម្ពុជា ក៏បានបន្តកិច្ចសហប្រតិបត្តិការ ជាមួយសហព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យម (FASMEC) ដើម្បីលើកកម្ពស់សុចរិតភាពធុរកិច្ចតាមបណ្តាលសហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា។

*លោក ប៉ិច ពិសី នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា មានប្រសាសន៍ថា៖ កិច្ចសហប្រតិបត្តិការរួមគ្នាតែងតែជាយុទ្ធសាស្ត្រស្នូលរបស់អង្គការតម្លាភាពកម្ពុជា។ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នដៃគូពាក់ព័ន្ធ ដែលមានដូចជារាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ និងសមាគមធុរកិច្ច ដែលពោរពេញទៅដោយជំនាញ និងបទពិសោធន៍ផ្សេងៗគ្នា នឹងរួមចំណែកដ៏សំខាន់ក្នុងការអនុវត្តគម្រោងប្រកបទៅដោយភាពជោគជ័យ។ អង្គការតម្លាភាពកម្ពុជា ឬអង្គការអាក់សិនអេតកម្ពុជាតែឯង មិនអាចធ្វើឱ្យគម្រោងនេះទទួលបានជោគជ័យបានឡើយ។ យើងជឿជាក់យ៉ាងមុតមាំថា យើងនឹងកាន់តែរឹងមាំ ហើយអនុវត្តគម្រោងបានកាន់តែល្អប្រសើរ នៅពេលដែលយើងមានគោលដៅច្បាស់លាស់ និងសហការជាមួយគ្នាល្អ។*

អង្គការតម្លាភាពកម្ពុជា និងអង្គការអាក់សិនអេតកម្ពុជា សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិនៃប្រទេសស៊ុយអែត (SIDA) និង សហភាពអឺរ៉ុប (EU) ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ រយៈពេល ៣ឆ្នាំ ដើម្បីអនុវត្តកម្មវិធីយុទ្ធសាស្ត្ររបស់យើង។ បើគ្មានការគាំទ្រទាំងនេះទេ យើងនឹងមិនអាចបន្តបេសកកម្មក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងការប្រឆាំងអំពើពុករលួយនៅប្រទេសកម្ពុជាឡើយ៕

**សម្រាប់ការធ្វើបទសម្ភាសន៍សូមទំនាក់ទំនង៖**


- លោក **ប៉ិច ពិសី** នាយកប្រតិបត្តិនៃអង្គការតម្លាភាពកម្ពុជា
  ទូរស័ព្ទលេខ៖ (៨៥៥) ០៨៩ ៩៧២ ៦២០ អ៊ីមែល៖ piseypech@ticambodia.org
- លោក **ហុង រស្មី** នាយកប្រចាំប្រទេសនៃអង្គការអាក់សិនអេតកម្ពុជា
  ទូរស័ព្ទលេខ៖ (៨៥៥) ១២ ២០០ ៣៤១ អ៊ីមែល៖ reaksmey.hong@actionaid.org